# ប្រកាសអន្តរក្រសួងលេខ ៣៧៧ សហវ ចុះថ្ងៃទី២៨/០៥/២០០២ ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/សន/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ភូមិបាល

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

- អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ។

- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យ សាធារណៈ

- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល

- តាមការចាំបាច់ក្នុងការអនុវត្តន៍ច្បាប់ភូមិបាល

## សំរេច

ប្រការ ១.- អនុញ្ញាតឱ្យយកសោហ៊ុយសេវាសុរិយោដីលើការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញប័ណ្ណទុតិយតា ការចេញប័ណ្ណតតិយតា ការផ្ទេរសិទ្ធិលើអចលនវត្ថុ ការចេញលិខិតបញ្ជាក់សុរិយោដី (ហ៊ីប៉ូតែក បញ្ចាំ ដាក់ធានា) ការចេញសលាកបត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី

និងការថតចម្លងឯកសារ ព្រមទាំងការបំពេញបែបបទឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងារសុរិយោដី ។

ប្រការ ២.- សោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់ដូចតទៅ ៖

| ល.រ | បរិយាយ | សោហ៊ុយសេវាសុរិយោដី | | |
|---|---|---|---|---|
| | | ដីផលិតកម្ម ឬ ដីភោគ | ដីលំនៅឋាន និងដីសំរាប់សំណង់ទូទៅ | |
| | | | ជនបទ ឬ ក្រៅក្រុង | ទីក្រុង ឬ ទីរួមខេត្ត |
| ១ | ការចេញប័ណ្ណ ឬប័ណ្ណទុតិយតា ឬប័ណ្ណតតិយតា ក្នុង ១ក្បាលដី | ៥,០០០៛០០ | ១០០,០០០៛០០ | ៣៥០,០០០៛០០ |
| ២ | ការផ្ទេរអចលនវត្ថុ (ផ្ទេរដោយបំបែក ឬផ្ទេរទាំងមូល) ក្នុង ១ប័ណ្ណ | ៥០,០០០៛០០ | ៨០,០០០៛០០ | ១០០,០០០៛០០ |
| ៣ | ការបង្រួមក្បាលដីក្នុង ១ក្បាលដី | ១០០,០០០៛០០ | ១២០,០០០៛០០ | ១៥០,០០០៛០០ |
| ៤ | ការចេញលិខិតបញ្ជាក់ (ហ៊ីប៉ូតែក ដាក់បញ្ចាំ ដាក់ធានា )ក្នុង ១ក្បាលដី | ១៥,០០០៛០០ | ១៨,០០០៛០០ | ២០,០០០៛០០ |
| ៥ | ការចេញសលាកបត្រព័ត៌មានក្នុង ១ក្បាលដី | ១៥,០០០៛០០ | ១៨,០០០៛០០ | ២០,០០០៛០០ |
| ៦ | ការចេញលិខិតបញ្ជាក់សុរិយោដីក្នុង ១ក្បាលដី | ១៥,០០០៛០០ | ១៨,០០០៛០០ | ២០,០០០៛០០ |

ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ សោហ៊ុយសេវាសុរិយោដី ជាបន្ទុករបស់អ្នកទទួលសិទ្ធិ ។

អ្នកទទួលសិទ្ធិអចលនវត្ថុ ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់សារពើពន្ធជាធរមាន ។

ប្រការ ៣.- សោហ៊ុយសេវាសុរិយោដីលើការវាស់វែងដីដោយប្រើឧបករណ៍ស្ទង់ទំនើបត្រូវបានកំណត់ដូចខាងក្រោម ៖

| លរ | បរិយាយ | សោហ៊ុយក្នុងមួយហិតា |
|---|---|---|
| 1 | ទំហំដីតិចជាង ១០ ហិតា | ៣០ ០០០ ៛ ០០ |
| 2 | ទំហំដីចាប់ពី ១០ ហិតា ដល់ ៥០ ហិតា | ១៥ ០០០ ៛ ០០ |
| 3 | ទំហំដីចាប់ពី ៥០ ហិតា ដល់ ៣០០ ហិតា | ១០ ០០០ ៛ ០០ |
| 4 | ទំហំដីចាប់ពី ៣០០ ហិតា ដល់ ១ ០០០ ហិតា | ៨ ០០០ ៛ ០០ |
| 5 | ទំហំដីចាប់ពី ១ ០០០ ហិតា ឡើងទៅ | ៦ ០០០ ៛ ០០ |

ចំពោះដីដែលមានទីតាំងឆ្ងាយលើសពី ៥០ គីឡូម៉ែត្រពីអង្គភាពសុរិយោដី ម្ចាស់ត្រូវទទួលបន្ទុកបន្ថែមលើ ៖

១. សោហ៊ុយធ្វើដំណើរ ស្នាក់នៅ ហូបចុក របស់មន្ត្រីជំនាញ ។

២. ថ្លៃបង្គោល និងការដាំបង្គោលព្រំ ។

៣. ចំពោះដំបន់ព្រៃភ្នំ សោហ៊ុយសុរិយោដីត្រូវគិតបន្ថែម ២០% លើសោហ៊ុយសេវាវាស់វែងសរុប ។

ប្រការ ៤.- រាល់ទម្រង់បែបបទឯកសារសុរិយោដី ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមនីតិវិធីសុរិយោដី ។

ប្រការ ៥.-

- ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមរយៈរជ្ជទេយ្យករចំណូល នៅថ្នាក់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ។

- ក្នុងករណីចាំបាច់មានការបង្កើតរជ្ជទេយ្យកររង នៅការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកខណ្ឌ ។

- ការបោះពុម្ព និងការបើកផ្តល់ប័ណ្ណកំណត់ពីសោហ៊ុយសេវាសុរិយោដីជាបន្ទុករបស់ថវិកាដែលចែងអនុវត្តដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

ប្រការ ៦.- ការគ្រប់គ្រងចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។

ប្រការ ៧.- ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបានកំណត់បែងចែកដូចខាងក្រោម ៖

១. ៧៥% សម្រាប់បង់ចូលថវិការដ្ឋក្នុងនោះមាន៣៥% ដែលជាចំណែករបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សម្រាប់ចាត់ចែងបែងចំណាយដល់អង្គភាពជំនាញសុរិយោដីក្រោមឱវាទ ។

២. ១៥% សម្រាប់ឱ្យគុណប្រយោជន៍ថវិការបស់ខេត្តក្រុង ក្នុងនោះមាន ៥% ដែលជាចំណែករបស់ស្រុកខណ្ឌ ។

៣. ១០% សម្រាប់បម្រើឱ្យគុណប្រយោជន៍ថវិការបស់ឃុំសង្កាត់ ។

ប្រការ ៨.- ចំណូលពីសោហ៊ុយសេវាសុរិយោដី ត្រូវបង់ចូលថវិការដ្ឋ និងថវិកាខេត្តក្រុង នៅរតនាគារខេត្តក្រុង ដោយកំណត់ត្រានៅក្នុងជំពូក ២១ ប្រការ ០៣ កថាខណ្ឌ១៩ ។ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីត្រូវបូកសរុបធ្វើរបាយការណ៍នៃចំណូលនេះជូនក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្នុងមួយត្រីមាសម្តង ដោយភ្ជាប់មកជាមួយនូវសលាកបត្របង់ប្រាក់ ។

ប្រការ ៩.- ផ្អែកលើការបូកសរុបសភាពការណ៍បង់ចំណូលប្រចាំត្រីមាស ដូចមានចែងក្នុងប្រការ ៨ ខាងលើ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវលើកសំណើសុំចំណាយក្នុងរង្វង់ ៣៥% នៃចំណូលដែលបានបង់ចូលថវិការដ្ឋ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេចផ្តល់ជូនតាមចំណែកដែលត្រូវបានទទួលជូនវិញ តែត្រូវភ្ជាប់មកជាមួយនូវ ៖

- សលាកបត្របង់ប្រាក់ចំណូលពីសោហ៊ុយសេវាសុរិយោដី

- របាយការណ៍ចំណាយនៃចំណែក ៣៥% ដែលថវិការដ្ឋបានបើកផ្តល់លើកមុន ដោយភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ និងត្រឹមត្រូវ ។

នីតិវិធីនៃការបើកផ្តល់ចំណាយត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយកត់ត្រានៅក្នុងជំពូក ១១. ០១.១៥.០២ ។

ប្រការ ១០.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រកាសនេះនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ១១.- អគ្គលេខាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ប្រធានរតនាគារជាតិ អង្គភាពពាក់ព័ន្ធទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ១២.- ប្រកាសនេះនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

កន្លែងទទួល

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អាជ្ញាធរសវនកម្មជាតិ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន

-គ្រប់សាលាខេត្ត-ក្រុង

ដើម្បីជូនជ្រាប

-ដូចប្រការ ១១ ដើម្បីអនុវត្ត

-ឯកសារ និងកាលប្បវត្តិ